**Alert.seattle.gov/winterstorm** (ការជូនដំណឹង.seattle.រដ្ឋាភិបាល/ព្យុះនារដូវត្រជាក់)

**ការណ៍ពិត ៖** តំបន់ Seattle នាពេលបច្ចុប្បន្ន កំពុងរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីអាកាសធាតុ រដូវត្រជាក់ ។ ការកើនឡើងនៃគំនរព្រិល និងសីតុណ្ហភាពត្រជាក់ អាចបង្កឧបសគ្គដល់ចរាចរណ៍ ដឹកជញ្ជូនជាធម្មតា មានសម្ពាធលើសមត្ថភាពរបស់យានយន្តសង្គ្រោះអាសន្ន ក្នុងការធ្វើដំណើរ និងបង្កើតភាពស្មុគស្មាញ សម្រាប់អ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ ។ ក្នុងកំឡុងពេលមានអាកាសធាតុត្រជាក់រយៈពេលយូរ បំពង់ទឹបនៅក្នុងផ្ទះ អាចកក ដែលបង្កបញ្ហាទឹក នៅតាមផ្ទះ និងអាគារផ្ទះល្វែង។

**អ្វីដែលត្រូវធ្វើ ៖**

- ស្លៀកពាក់ឱ្យបានច្រើនជាន់ ដើម្បីឱ្យងំកំដៅ ហើយរក្សាសម្លៀកបំពាក់ឱ្យនៅស្ងួតល្អ ។ ពាក់មួក ដើម្បីការពារមិនឱ្យបាត់បង់កំដៅរាងកាយ ។
- ប្រើម៉ាស៊ីនរំលាយទឹកកក ដើម្បីធ្វើឱ្យទឹកកក នៅលើផ្លូវដើរ និងផ្លូវបើកបរ រលាយ ។
- រក្សាទុកគ្រឿងទេស និងគ្រឿងផ្គត់ផ្គង់ ឱ្យបានច្រើន ដោយហាងលក់ទំនិញ អាចប្រើពេលវេលាច្រើន ដើម្បីផ្ទុកបំពេញទំនិញឡើងវិញ ។
- ជៀសវាងការប្រើកម្លាំងប្រឹងខ្លាំងជ្រុល នៅពេលចូកព្រិលចោល ។ ចូករុញព្រិលចោល ជាជាងចូកវាហើយលើកយកទៅចាក់ចោល តាមដែលអាចធ្វើទៅបាន ។
- រំពឹងថា មានការពន្យារពេល នៅពេលធ្វើដំណើរ និងមានការផ្លាស់ប្តូរ ចំពោះផ្លូវឆ្លងកាត់សាធារណៈធម្មតា ។
- ត្រៀមលក្ខណៈ សម្រាប់ពេលដាច់ចរន្តអគ្គិសនី និងរៀបចំបង្ការ នៅពេលប្រើប្រាស់វិធីកំដៅជាជម្រើសផ្សេងទៀត ។
- ស្តាប់វិទ្យុ ដើម្បីទទួលបានបច្ចុប្បន្នភាព ពីព័ត៌មានស្តីពីគ្រោះអាសន្ន ។
- ***ប្រសិនបើលោកអ្នកស្គាល់បុគ្គលដែលមិនអាច យល់ មើលឃើញ ឬដឹងឮ អំពីសារនេះបានទេសូមជួយប្រាប់ពួកគេផង ។***

**គំណរបណ្តាញដែលមានប្រយោជន៍ ៖**

http://www.seattle.gov/emergency-management/what-if/hazards/snow-ice-and-extreme-cold

http://www.seattle.gov/light/sysstat/

http://www.ready.gov/winter-weather

http://www.redcross.org/prepare/disaster/winter-storm